ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២០៧ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការគ្រប់គ្រងថ្នាលសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៤៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីហត្ថលេខាឌីជីថល
- បានឃើញអនុក្រឹត្យលេខ ១៦៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ ស្តីពីការផ្លាស់ប្តូរទិន្នន័យតាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៥៣ អនក្រ.បក ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការគ្រប់គ្រង ការប្រើ-ប្រាស់ និងការការពារសុវត្ថិភាពទិន្នន័យ អត្តសញ្ញាណបុគ្គល
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- យោងតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់អំពីយន្តការ វិធាន និងនីតិវិធីនៃការគ្រប់គ្រងថ្នាលសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថលកម្ពុជា ដែលសរសេរជាអក្សរកាត់ថា "**អ.ឌ.ក.**" និងមានឈ្មោះជាភាសាអង់គ្លេសថា Cambodia Digital Key - CamDigiKey) ប្រកបដោយសុវត្ថិភាព គណនេយ្យភាព និងតម្លាភាព។

**មាត្រា២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែលរដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល នីតិបុគ្គលទទួលផលប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈ ក្រុមហ៊ុនឬសហគ្រាសពាណិជ្ជកម្ម និងសមាគម ដែលត្រូវបានបង្កើតស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងរូបវន្តបុគ្គលមានសញ្ជាតិខ្មែរនិងរូបវន្តបុគ្គលមានសញ្ជាតិបរទេស ដែលប្រើប្រាស់សេវានិងទិន្នន័យនៃ **អ.ឌ.ក.** លើកលែងតែការប្រើប្រាស់សេវានិងទិន្នន័យក្នុងវិស័យការពារជាតិ សន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ។

**មាត្រា៣.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី២

## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៤.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការដឹកនាំនិងការគ្រប់គ្រង **អ.ឌ.ក.** ដើម្បីជំរុញការចាប់យក ការប្រើប្រាស់ និងការធ្វើបរិវត្តកម្មប្រព័ន្ធសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថលនៅក្នុងគ្រប់តួអង្គសង្គម សំដៅជំរុញសន្ទុះនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជារស់រវើក ដែលមានភារកិច្ចដូចខាងក្រោម៖

- រៀបចំនិងអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រពាក់ព័ន្ធនឹងការតម្រង់ទិសអនុវត្តនិងធ្វើវិបុលកម្ម **អ.ឌ.ក.**
- សហការរៀបចំធ្វើវិសោធនកម្ម និងអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតពាក់ព័ន្ធនឹង **អ.ឌ.ក.**
- ជំរុញការអនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតពាក់ព័ន្ធនឹង **អ.ឌ.ក.** ប្រកបដោយប្រសិទ្ធភាព
- អភិវឌ្ឍនិងនវានុវត្ត **អ.ឌ.ក.** បន្ថែម ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជាឥតឈប់ឈរ ព្រមទាំងនិន្នាការថ្មីៗនៃការធ្វើបរិវត្តកម្មឌីជីថលនិងប្រព័ន្ធសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថលក្នុងបរិការណ៍តំបន់និងសកល
- ពង្រឹងអភិបាលកិច្ចឌីជីថលផ្អែកលើ **អ.ឌ.ក.** ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន

គេហទំព័រ ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

- ដឹកនាំ សម្របសម្រួល និងសហការរៀបចំក្របខណ្ឌនិងយន្តការសុខដុមនីយកម្មមុខងារនិងភារកិច្ច ព្រមទាំងដោះស្រាយបញ្ហាផ្សេងៗដែលមានលក្ខណៈអន្តរក្រសួង ស្ថាប័នពាក់ព័ន្ធនឹង **អ.ឌ.ក**. ប្រកបដោយស្មារតីសហការទទួលខុសត្រូវ សហថាមភាព និងសិនិទ្ធភាពជាមួយនឹងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ
- លើកកម្ពស់ការការពារសន្តិសុខតាមបច្ចេកវិទ្យាព័ត៌មាននិងសុវត្ថិភាពទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក**. ដើម្បីលើកកម្ពស់ភាពជឿទុកចិត្តលើ **អ.ឌ.ក**. ដោយសហការជាមួយនឹងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារនិងសមិទ្ធផល បញ្ហាប្រឈម និងការស្នើឡើងនូវវិធានការដោះស្រាយជូនរាជរដ្ឋាភិបាល
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីរាជរដ្ឋាភិបាល។

**មាត្រា៥.-**

ប្រតិបត្តិករថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ដែលសរសេរជាអក្សរកាត់ថា "**ថ.ផ.ឌ**." (Cambodia Data Exchange - CamDX) ត្រូវបំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើប្រតិបត្តិការ **អ.ឌ.ក**. ដែលមានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលការស្នើសុំបង្កើតគណនីអត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក**. កែតម្រូវ ឬលុបទិន្នន័យចេញពី **អ.ឌ.ក**.
- ពិនិត្យ ផ្ទៀយថាភូតកម្ម និងបង្កើតគណនីអត្តសញ្ញាណអតិថិជនឌីជីថលរបស់រូបវន្តបុគ្គលមានសញ្ជាតិខ្មែរនិងរូបវន្តបុគ្គលមានសញ្ជាតិបរទេស
- ពិនិត្យនិងសម្រេចលើការស្នើសុំរបស់សមាជិកភាពដោយការស្នើសុំ ដែលមានបំណងផ្ទៀយថាភូតកម្ម និង ប្រើប្រាស់ទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក**.
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការផ្តល់និងចែកចាយទិន្នន័យទៅកាន់សមាជិកភាពដោយស្វ័យប្រវត្តិនិងសមាជិកភាពដោយការស្នើសុំ ដើម្បីអាចប្រើប្រាស់ក្នុងការផ្ទៀយថាភូតកម្មអត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក**. ដោយផ្អែកលើការយល់ព្រមរបស់ម្ចាស់គណនីអត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក**.
- កំណត់អំពីបែបបទ វិធាន និងនីតិវិធីនៃការស្នើសុំសមាជិកភាពរបស់សមាជិកភាព ដែលមានបំណងផ្ទៀយថាភូតកម្ម និង ប្រើប្រាស់ទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក**.
- សម្របសម្រួល ពិនិត្យ និងសម្រេចលើដំណើរការនីតិវិធីនៃការស្នើសុំឈប់ផ្ទៀយថាភូតកម្ម និង ប្រើប្រាស់ទិន្នន័យពី **អ.ឌ.ក**.
- បញ្ចប់សមាជិកភាពរបស់សមាជិកភាពដោយការស្នើសុំក្នុងករណីសមាជិកភាពដោយការស្នើសុំនេះមិនគោរពតាមមាត្រា២៦នៃអនុក្រឹត្យនេះ
- ចាត់វិធានការការពារសន្តិសុខតាមបច្ចេកវិទ្យាព័ត៌មាន និង សុវត្ថិភាពទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក**. អនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន
- សហការជាមួយនឹងសមាជិកភាពដោយស្វ័យប្រវត្តិនិងសមាជិកភាពដោយការស្នើសុំ ដែលផ្ទៀយថាភូត-

កម្ម និង ប្រើប្រាស់ទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ត**. ក្នុងការរៀបចំ ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃសន្តិសុខប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៃ **អ.ឌ.ត**. ដោយស្ថាប័នជំនាញតាមការចាំបាច់

- អនុវត្តតាមរបាយការណ៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងចាត់វិធានការចាំបាច់នានា ដើម្បីកែលម្អចំណុចខ្វះខាតដែលគំរាមកំហែងឬដែលអាចគំរាមកំហែងដល់សន្តិសុខប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៃ **អ.ឌ.ត**.
- ប្រមូលកម្រៃសេវាដែលបានមកពីការផ្ទៀងផ្ទាត់ភូតកម្មអត្តសញ្ញាណអតិថិជនឌីជីថល និង ចែករំលែកទិន្នន័យផ្ទាល់ខ្លួនរបស់ម្ចាស់គណនីអត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ត**.
- សម្របសម្រួលការដោះស្រាយវិវាទពាក់ព័ន្ធនឹងការផ្ទៀងផ្ទាត់ភូតកម្មអត្តសញ្ញាណអតិថិជនឌីជីថល និង ការចែករំលែកទិន្នន័យផ្ទាល់ខ្លួនរបស់ម្ចាស់គណនីអត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ត**.
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ឱ្យពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៦.-**

ក្រសួងមហាផ្ទៃមានភារកិច្ចចូលរួមផ្តល់ទិន្នន័យ អត្តសញ្ញាណបុគ្គលមកកាន់ **អ.ឌ.ត**. ដើម្បីធ្វើការផ្ទៀងផ្ទាត់បង្កើតគណនីអត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ត**។

## ជំពូកទី៣
## ការស្នើសុំបង្កើតគណនីអត្តសញ្ញាណអតិថិជនឌីជីថលនៃ អ.ឌ.ត.

**មាត្រា៧.-**

រូបវន្តបុគ្គលមានសញ្ជាតិខ្មែរមានសិទ្ធិស្នើសុំបង្កើតគណនីអត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ត**. ដើម្បីទទួលបាន និង ប្រើប្រាស់សេវាឌីជីថល ដែលធ្វើប្រតិបត្តិការតាម **ថ.ផ.ទ**. និងតភ្ជាប់មកកាន់ **អ.ឌ.ត**. ដោយឆ្លងកាត់ដំណើរការនៃការបង្កើតគណនីតាមរយៈ **អ.ឌ.ត**. និងផ្តល់ទិន្នន័យពិតប្រាកដរបស់ខ្លួនពាក់ព័ន្ធនឹងមុខ ភាពរស់រវើកនៃមុខ លេខអត្តសញ្ញាណប័ណ្ណ ឈ្មោះជាភាសាខ្មែរ ឈ្មោះជាអក្សរឡាតាំង ភេទ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត លេខទូរស័ព្ទ និងអាសយដ្ឋានបច្ចុប្បន្ន ដែលមានសុពលភាព មកប្រតិបត្តិករ **ថ.ផ.ទ**. ដើម្បីពិនិត្យ ផ្ទៀងផ្ទាត់ភូតកម្ម និងបង្កើតគណនីអត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ត**។

**មាត្រា៨.-**

រូបវន្តបុគ្គលមានសញ្ជាតិបរទេសដែលមានបំណងបង្កើតគណនីអត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ត**. ដើម្បីទទួលបាន និង ប្រើប្រាស់សេវាឌីជីថល ដែលធ្វើប្រតិបត្តិការតាម **ថ.ផ.ទ**. និងតភ្ជាប់មកកាន់ **អ.ឌ.ត**. ដោយឆ្លងកាត់ដំណើរការនៃការបង្កើតគណនីតាមរយៈ **អ.ឌ.ត**. ត្រូវមានលិខិតឆ្លងដែនបរទេស និង ផ្តល់ទិន្នន័យពិតប្រាកដរបស់ខ្លួនពាក់ព័ន្ធនឹងមុខ ភាពរស់រវើកនៃមុខ លេខលិខិតឆ្លងដែន ឈ្មោះជាអក្សរឡាតាំង ភេទ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត លេខទូរស័ព្ទ សញ្ជាតិបរទេស និងអាសយដ្ឋានបច្ចុប្បន្ន ដែលមានសុពលភាព មកប្រតិបត្តិករ **ថ.ផ.ទ**. ដើម្បីពិនិត្យ ផ្ទៀងផ្ទាត់ភូតកម្ម និងបង្កើតគណនីអត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ត**។

**មាត្រា៩.-**

ការស្នើសុំបង្កើតគណនីអត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ត**. របស់រូបវន្តបុគ្គលមានសញ្ជាតិខ្មែរនិងរូបវន្តបុគ្គលមានសញ្ជាតិបរទេស អាចត្រូវបានបដិសេធក្នុងករណីដែលការស្នើសុំបង្កើតគណនីនេះមិនបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា៧និងមាត្រា៨នៃអនុក្រឹត្យនេះ។



គេហទំព័រ ឯកសារផ្លូវការ: - https://t.me/oa_channel

**មាត្រា១០.-**

ម្ចាស់គណនីអត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** ដែលមានបំណងកែតម្រូវឬលុបទិន្នន័យអត្តសញ្ញាណរបស់ខ្លួនពី **អ.ឌ.ក.** ត្រូវស្នើសុំកែតម្រូវឬលុបទិន្នន័យ អត្តសញ្ញាណរបស់ខ្លួន តាមរយៈ **អ.ឌ.ក.** ទៅប្រតិបត្តិករ **ថ.ផ.ឌ.**។

ប្រតិបត្តិករ **ថ.ផ.ឌ.** មានធន្ទានុសិទ្ធិទទួលយកឬបដិសេធការស្នើសុំកែតម្រូវឬលុបទិន្នន័យ អត្ត-សញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** តាមប្រព័ន្ធរបស់ **អ.ឌ.ក.** ដោយផ្អែកលើហេតុផលសមស្រប តាមការស្នើសុំរបស់ម្ចាស់គណនីអត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** ឬតំណាងស្របច្បាប់របស់ម្ចាស់គណនីអត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.**។

**មាត្រា១១.-**

បន្ទាប់ពីការស្នើសុំបង្កើតគណនីអត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** រូបវន្តបុគ្គលមានសញ្ជាតិខ្មែរនិងរូបវន្តបុគ្គលមានសញ្ជាតិបរទេសអាចបញ្ចូលទិន្នន័យផ្ទាល់ខ្លួនបន្ថែមទៀតទៅក្នុង **អ.ឌ.ក.** តាមការស្ម័គ្រចិត្ត ដើម្បីជួយសម្រួលដល់ការប្រើប្រាស់ទិន្នន័យ។

**មាត្រា១២.-**

ការបង្កើតគណនីនិងការកែតម្រូវឬការលុបទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** ត្រូវស្របតាមបែបបទ វិធាន និងនីតិវិធី ដែលត្រូវដាក់ឱ្យអនុវត្តដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៣.-**

រាល់ទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** ត្រូវបានធានានូវសុវត្ថិភាព ឯកជនភាព ការសម្ងាត់ សុចរិតភាព និងសុក្រឹតភាព ព្រមទាំងត្រូវបានធ្វើកំណត់ត្រាអេឡិចត្រូនិកពីការបង្កើតគណនី និងការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃ... 

**មាត្រា១៤.-**

រាល់ទិន្នន័យដែលបញ្ចូលទៅក្នុង **អ.ឌ.ក.** ដោយម្ចាស់គណនីអត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** ត្រូវបានរក្សាទុកក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៃ **អ.ឌ.ក.**។

## ជំពូកទី៤
## ការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ និង ការប្រើប្រាស់
## ទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ អ.ឌ.ក.

**មាត្រា១៥.-**

ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល នីតិបុគ្គលទទួលផលប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈ ក្រុមហ៊ុនឬសហគ្រាសពាណិជ្ជកម្ម និងសមាគម ដែលមានបំណងផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ និង ប្រើប្រាស់ទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថល តាមរយៈ **អ.ឌ.ក.** ត្រូវតែជាសមាជិកភាពរបស់ **ថ.ផ.ឌ.**។ សមាជិកភាពរបស់ **ថ.ផ.ឌ.** មានសមាជិកភាពដោយស្វ័យប្រវត្តិនិងសមាជិកភាពដោយការស្នើសុំ។

សមាជិកភាពដោយស្វ័យប្រវត្តិ សំដៅដល់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងនីតិបុគ្គលទទួលផល

ប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈ។ សមាជិកភាពដោយការស្នើសុំ សំដៅដល់ក្រុមហ៊ុនឬសហគ្រាសពាណិជ្ជកម្ម និងសមាគម ដែលបានចុះបញ្ជីត្រឹមត្រូវស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

លក្ខខណ្ឌដើម្បីក្លាយជាសមាជិកភាពដោយស្វ័យប្រវត្តិនិងសមាជិកភាពដោយការស្នើសុំ ត្រូវកំណត់ដោយអនុក្រឹត្យពាក់ព័ន្ធការផ្លាស់ប្តូរទិន្នន័យតាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា។

**មាត្រា១៦.-**

សមាជិកភាពដោយការស្នើសុំរបស់ **ថ.ផ.ទ.** ដែលមានបំណងធ្វើយថាភូតកម្មទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** អាចស្នើសុំការអនុញ្ញាតពីប្រតិបត្តិករ **ថ.ផ.ទ.** ក្នុងការធ្វើយថាភូតកម្មទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** តាមប្រព័ន្ធអេឡិចត្រូនិក ដោយប្រើប្រាស់ប្រព័ន្ធធ្វើយថាភូតកម្មនៃ **អ.ឌ.ក.** ដើម្បីប្រើប្រាស់ក្នុងបុព្វហេតុបម្រើឱ្យការផ្តល់សេវាឌីជីថលនិងបម្រើផលប្រយោជន៍ស្របច្បាប់។

**មាត្រា១៧.-**

សមាជិកភាពដោយការស្នើសុំរបស់ **ថ.ផ.ទ.** ដែលស្នើសុំការអនុញ្ញាតពីប្រតិបត្តិករ **ថ.ផ.ទ.** ក្នុងការធ្វើយថាភូតកម្មទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** អាចទទួលនិងប្រើប្រាស់ទិន្នន័យដូចមានចែងក្នុងមាត្រា៧ មាត្រា៨ និងមាត្រា១១នៃអនុក្រឹត្យនេះ។

**មាត្រា១៨.-**

ការប្រើប្រាស់ទិន្នន័យដូចមានចែងក្នុងមាត្រា៧ មាត្រា៨ និងមាត្រា១១នៃអនុក្រឹត្យនេះ ត្រូវមានការយល់ព្រមពីម្ចាស់គណនីអត្តសញ្ញាណអតិថិជនឌីជីថលរាល់ពេលដែលទិន្នន័យត្រូវបានប្រើប្រាស់ តាមរយៈ **អ.ឌ.ក.**។

រូបវន្តបុគ្គលដែលជាអតិថិជនឌីជីថលនៃ **អ.ឌ.ក.** មានសិទ្ធិដឹងព័ត៌មានអំពីការប្រើប្រាស់ទិន្នន័យអត្តសញ្ញាណ និងទិន្នន័យផ្ទាល់ខ្លួនរបស់ខ្លួន។

**មាត្រា១៩.-**

ការស្នើសុំធ្វើយថាភូតកម្ម និង ការប្រើប្រាស់ទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** ជាកម្មវត្ថុនៃការបង់កម្រៃសេវាដូចមានចែងក្នុងមាត្រា៣២និងមាត្រា៣៣នៃអនុក្រឹត្យនេះ។

**មាត្រា២០.-**

ដើម្បីទទួលបាននីតិសម្បទាក្នុងការធ្វើយថាភូតកម្ម និង ការប្រើប្រាស់ទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** សមាជិកភាពដោយការស្នើសុំរបស់ **ថ.ផ.ទ.** ត្រូវបំពេញលក្ខខណ្ឌអប្បបរមា ដូចខាងក្រោម៖

- ត្រូវប្រើប្រាស់ទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** ដែលត្រូវបានធ្វើយថាភូតកម្មឱ្យស្របតាមគោលបំណងនៃការផ្តល់សេវាឌីជីថលនិងបម្រើផលប្រយោជន៍ស្របច្បាប់ ស្របតាមអនុស្សរណៈនៃការយោគយល់គ្នាជាមួយនឹងប្រតិបត្តិករ **ថ.ផ.ទ.** ព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន
- ត្រូវមានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលធានាបាននូវគុណភាពនិងសុវត្ថិភាព
- ត្រូវមានហេដ្ឋារចនាសម្ព័ន្ធបណ្តាញ និង សម្ភារបរិក្ខារបច្ចេកវិទ្យាព័ត៌មាន ដើម្បីត្រៀមបម្រុងសម្រាប់ប្រតិបត្តិការ ធានាបាននូវសន្តិសុខ សុវត្ថិភាព សុក្រឹតភាព និងគុណភាពនៃប្រព័ន្ធ



គេហទំព័រព្រាប ឯកសារផ្លូវការ - https://t.me/oa_channel

- ត្រូវដំឡើងសេវូបករណ៍សុវត្ថិភាពក្នុងបណ្តាញប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ខ្លួន
- ត្រូវចូលរួមសហការជាមួយនឹងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធក្នុងការចាត់វិធានការឆ្លើយតបទៅនឹងការវាយប្រហារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- ត្រូវរៀបចំនិងផ្តល់របាយការណ៍នៃការធ្វើយថាភូតកម្ម និង ការប្រើប្រាស់ទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ មកប្រតិបត្តិករ **ថ.ផ.ឆ.** ដើម្បីជាមូលដ្ឋានក្នុងការចាត់វិធានការ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**មាត្រា២១.-**

សមាជិកភាពដោយស្វ័យប្រវត្តិនិងសមាជិកភាពដោយការស្នើសុំរបស់ **ថ.ផ.ឆ.** ត្រូវអនុវត្តតាមបែបបទវិធាន និងនីតិវិធីនៃការធ្វើយថាភូតកម្ម និង ការប្រើប្រាស់ទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** ដែលត្រូវដាក់ឱ្យអនុវត្តដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២២.-**

ការធ្វើយថាភូតកម្មអត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** មិនមានអានុភាពប្រើប្រាស់ជំនួសអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរនិងលិខិតឆ្លងដែនបរទេស ដែលត្រូវកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

ការធ្វើយថាភូតកម្មនិងការប្រើប្រាស់អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** មិនមែនជាភស្តុតាងដែលបញ្ជាក់អំពីភាពជាពលរដ្ឋឬទីកន្លែងស្នាក់នៅនៃអតិថិជននោះទេ។

**មាត្រា២៣.-**

សមាជិកភាពដោយការស្នើសុំរបស់ **ថ.ផ.ឆ.** ដែលមានបំណងឈប់ប្រើប្រាស់ទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** ដូចមានចែងក្នុងមាត្រា៧ មាត្រា៨ និងមាត្រា១១នៃអនុក្រឹត្យនេះ ត្រូវបំពេញពាក្យស្នើសុំឈប់ប្រើប្រាស់ទិន្នន័យនេះដោយស្នើសុំទៅប្រតិបត្តិករ **ថ.ផ.ឆ.**។

ប្រតិបត្តិករ **ថ.ផ.ឆ.** ត្រូវសម្របសម្រួលដំណើរការនីតិវិធីនៃការស្នើសុំឈប់ប្រើប្រាស់ទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** និងជូនដំណឹងអំពីការស្នើសុំលាឈប់ប្រើប្រាស់ទិន្នន័យនេះទៅកាន់សមាជិកភាពរបស់ **ថ.ផ.ឆ.** ដទៃទៀត។

ការឈប់ធ្វើយថាភូតកម្ម និង ប្រើប្រាស់ទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** ត្រូវមានអានុភាពដោយគិតចាប់ពីថ្ងៃទទួលបានសេចក្តីជូនដំណឹងស្តីពីការបញ្ចប់នីតិសម្បទាក្នុងការធ្វើយថាភូតកម្មនិងការប្រើប្រាស់ទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** ដែលចេញដោយប្រតិបត្តិករ **ថ.ផ.ឆ.**។

**មាត្រា២៤.-**

ប្រតិបត្តិករ **ថ.ផ.ឆ.** មានសិទ្ធិបញ្ចប់សមាជិកភាពរបស់សមាជិកភាពដោយការស្នើសុំណាមួយក្នុងករណីសមាជិកភាពដោយការស្នើសុំនោះមិនគោរពតាមមាត្រា២៦នៃអនុក្រឹត្យនេះ។

## ជំពូកទី៥
## ការការពារសន្តិសុខតាមបច្ចេកវិទ្យាព័ត៌មាន និងសុវត្ថិភាពទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ អ.ឌ.ក.

**មាត្រា២៥.-**

ការវាយប្រហារតាមបច្ចេកវិទ្យាព័ត៌មាន និងសុវត្ថិភាពទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថល ដែលតម្រូវឱ្យមានវិធានការការពារសន្តិសុខតាមបច្ចេកវិទ្យាព័ត៌មាន និង សុវត្ថិភាពទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថល រួមមានជាអាទិ៍ដូចខាងក្រោម៖

- ការជ្រៀតចូលឬការព្យាយាមជ្រៀតចូលតាមគ្រប់រូបភាពទៅក្នុង **អ.ឧ.ក**. និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់សមាជិកភាពដោយស្វ័យប្រវត្តិនិងសមាជិកភាពដោយការស្នើសុំ ដែលស្នើសុំធ្វើយថាភូតកម្ម និង ប្រើប្រាស់ទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឧ.ក**.
- ការវាយលុកឬការព្យាយាមវាយលុកដែលធ្វើឱ្យអាក់រអួលដល់ប្រតិបត្តិការ **អ.ឧ.ក**. និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់សមាជិកភាពដោយស្វ័យប្រវត្តិនិងសមាជិកភាពដោយការស្នើសុំ ដែលស្នើសុំធ្វើយថាភូតកម្ម និង ប្រើប្រាស់ទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឧ.ក**.
- ការប្រមូល ការថតចម្លង ការកែប្រែ ការប្រើប្រាស់ ការបង្ហាញ ការបញ្ជូន ការផ្សព្វផ្សាយ និង/ឬការធ្វើឱ្យបែកធ្លាយទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឧ.ក**. ដោយគ្មានការអនុញ្ញាត
- ការលួចយក ការបំផ្លាញ ការលុប ការធ្វើឱ្យបាត់បង់ ឬការធ្វើឱ្យខូចខាតទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឧ.ក**. ដោយចៃដន្យឬដោយចេតនា
- ការក្លែងបន្លំឬការប៉ុនប៉ងក្លែងបន្លំទិន្នន័យអត្តសញ្ញាណបុគ្គលដទៃដោយផ្ដល់ទិន្នន័យមិនពិត
- ការបញ្ចូលមេរោគ ការផ្ញើសារគំរាមកំហែង ការចាប់ជំរិត និង/ឬការធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសេដ្ឋកិច្ចនិងសង្គមឌីជីថល
- ការសមគំនិតឬការផ្ដល់មធ្យោបាយឬការផ្ដល់វិធីសាស្ត្រក្នុងការវាយប្រហារប្រព័ន្ធប្រតិបត្តិការ **អ.ឧ.ក**. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់សមាជិកភាពដោយស្វ័យប្រវត្តិនិងសមាជិកភាពដោយការស្នើសុំ ដែលស្នើសុំធ្វើយថាភូតកម្ម និង ប្រើប្រាស់ទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឧ.ក**. និងទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថល
- ការវាយប្រហារផ្សេងៗទៀតដែលបង្កហានិភ័យដល់សន្តិសុខប្រព័ន្ធអន្តរប្រតិបត្តិការនិងសុវត្ថិភាពទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលតាមរយៈ **អ.ឧ.ក**.។

**មាត្រា២៦.-**

ប្រតិបត្តិករ **ថ.ផ.ឌ**. ត្រូវចាត់វិធានការការពារសន្តិសុខតាមបច្ចេកវិទ្យាព័ត៌មាននិងសុវត្ថិភាពទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឧ.ក**. អនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន ដូចខាងក្រោម៖

- ត្រូវឱ្យសមាជិកភាពដោយស្វ័យប្រវត្តិនិងសមាជិកភាពដោយការស្នើសុំ រៀបចំនិងផ្ដល់របាយការណ៍នៃការធ្វើយថាភូតកម្ម និង ការប្រើប្រាស់ទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឧ.ក**. ដើម្បីជាមូលដ្ឋានក្នុងការចាត់វិធានការប្រឆាំងនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញ-ប្បទានដល់ការរីកសាយអាវុធមហាប្រល័យ និងវិធានការសន្តិសុខនិងសុវត្ថិភាពផ្សេងទៀត
- ស្វែងរក ប្រមូល ចម្លង និងរក្សាទុកទិន្នន័យកុំព្យូទ័រចាំបាច់សម្រាប់ធ្វើជាមូលដ្ឋានបញ្ជាក់អំពីភស្តុតាងឬការធ្វើយថាភូតកម្មអ្នកប្រព្រឹត្តអំពើវាយប្រហារ ដើម្បីជាគុណប្រយោជន៍ដល់ការតាមដាន ការ-ត្រួតពិនិត្យ ការស៊ើបអង្កេត ការស្រាវជ្រាវ និងការស្វែងរកអំពើដែលជាការវាយប្រហារសន្តិសុខតាមបច្ចេកវិទ្យាព័ត៌មាននិងសុវត្ថិភាពទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឧ.ក**. ព្រមទាំងការត្រួតពិនិត្យការពារសន្តិសុខតាមបច្ចេកវិទ្យាព័ត៌មាន និងសុវត្ថិភាពទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថល នៃ **អ.ឧ.ក**.



គេហទំព័រ ឯកសារមន្ត្រីរាជការ - https://t.me/oa_channel

- តាមដាន ត្រួតពិនិត្យ ស៊ើបអង្កេត ស្រាវជ្រាវ និងស្វែងរកអំពើវាយប្រហារសន្តិសុខតាមបច្ចេកវិទ្យាព័ត៌មាននិងសុវត្ថិភាពទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.**
- ត្រួតពិនិត្យការពារសន្តិសុខតាមបច្ចេកវិទ្យាព័ត៌មាននិងសុវត្ថិភាពទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.**
- ចាត់វិធានការសន្តិសុខនិងសុវត្ថិភាពផ្សេងទៀតអនុលោមច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

ក្នុងការចាត់វិធានការការពារសន្តិសុខតាមបច្ចេកវិទ្យាព័ត៌មាននិងសុវត្ថិភាពទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** ប្រតិបត្តិករ **ថ.ផ.ទ.** អាចសហការជាមួយនឹងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់។

**មាត្រា២៧.-**

សមាជិកភាពដោយស្វ័យប្រវត្តិនិងសមាជិកភាពដោយការស្នើសុំ ត្រូវមានវិធានការការពារសន្តិសុខតាមបច្ចេកវិទ្យាព័ត៌មានរៀងៗខ្លួន ក្នុងការទប់ស្កាត់ការវាយប្រហារតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទៅលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ខ្លួនដែលប៉ះពាល់ ឬដែលអាចប៉ះពាល់ដល់សន្តិសុខតាមបច្ចេកវិទ្យាព័ត៌មាន និងសុវត្ថិភាពទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** ដែលការពារដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

សមាជិកភាពដោយស្វ័យប្រវត្តិនិងសមាជិកភាពដោយការស្នើសុំ ត្រូវរាយការណ៍ជូនប្រតិបត្តិករ **ថ.ផ.ទ.** ពីហានិភ័យដែលប៉ះពាល់ឬដែលអាចប៉ះពាល់ដល់សន្តិសុខតាមបច្ចេកវិទ្យាព័ត៌មាននិងសុវត្ថិភាពទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** និងត្រូវសហការជាមួយនឹងប្រតិបត្តិករ **ថ.ផ.ទ.** ក្នុងការចាត់វិធានការដោះស្រាយហានិភ័យនេះ។

**មាត្រា២៨.-**

ម្ចាស់ទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** ត្រូវធានាសុវត្ថិភាពទិន្នន័យរបស់ខ្លួន ក្នុងករណីម្ចាស់ទិន្នន័យនោះអនុញ្ញាតឱ្យបុគ្គលដទៃគ្រប់គ្រង និង ប្រើប្រាស់ទិន្នន័យរបស់ខ្លួនក្នុងនាមខ្លួនឬដើម្បីបុព្វហេតុណាមួយ។

**មាត្រា២៩.-**

ប្រតិបត្តិករ **ថ.ផ.ទ.** និងសមាជិកភាពដោយស្វ័យប្រវត្តិនិងសមាជិកភាពដោយការស្នើសុំ ត្រូវសហការរៀបចំឱ្យមានការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើសន្តិសុខប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៃ **អ.ឌ.ក.** ដោយស្ថាប័នជំនាញ តាមការចាំបាច់។ ប្រតិបត្តិករ **ថ.ផ.ទ.** ត្រូវអនុវត្តតាមរបាយការណ៍ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ និងចាត់វិធានការចាំបាច់នានាដើម្បីកែលម្អចំណុចខ្វះខាត ដែលគំរាមកំហែងឬដែលអាចគំរាមកំហែងដល់សន្តិសុខប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៃ **អ.ឌ.ក.**។

**មាត្រា៣០.-**

បែបបទ វិធាន នីតិវិធី និងលក្ខខណ្ឌបច្ចេកទេសនៃការការពារសន្តិសុខតាមបច្ចេកវិទ្យាព័ត៌មាននិងសុវត្ថិភាពទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៦
## កម្រៃសេវា

**មាត្រា៣១.-**

សមាជិកភាពដោយស្វ័យប្រវត្តិនិងសមាជិកភាពដោយការស្នើសុំ ដែលស្នើសុំផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ និង ប្រើប្រាស់ទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** ត្រូវទទួលខុសត្រូវលើចំណាយប្រតិបត្តិការ តភ្ជាប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ខ្លួនមកកាន់ **អ.ឌ.ក.** ដែលរួមមានជាអាទិ៍ហេដ្ឋារចនាសម្ព័ន្ធ បណ្តាញ សម្ភារបរិក្ខារអេឡិចត្រូនិក និងធនធានមនុស្ស។

**មាត្រា៣២.-**

ការស្នើសុំផ្ទៀងផ្ទាត់ភាពត្រឹមត្រូវទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** ដើម្បីប្រើប្រាស់ក្នុង គោលបំណងស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវរាប់ជាចំនួនប្រតិបត្តិការ។

ការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថល និង ការប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនរបស់ អតិថិជនឌីជីថលនៃ **អ.ឌ.ក.** ក្នុងវិស័យសាធារណៈ គឺមិនត្រូវបានយកកម្រៃសេវានោះឡើយ។

បែបបទ វិធាន និងនីតិវិធី នៃការកំណត់ និង ការបង់កម្រៃសេវាពីការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនិងការប្រើប្រាស់ ទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ដោយឡែក បែបបទ វិធាន និងនីតិវិធី នៃការកំណត់ និង ការបង់កម្រៃសេវាពីការផ្ទៀងផ្ទាត់ ជាមួយទិន្នន័យ អត្តសញ្ញាណបុគ្គលដោយផ្ទាល់ របស់ក្រសួងមហាផ្ទៃ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣៣.-**

កម្រៃសេវាដែលបានមកពីការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** និងចំណូលពាក់ព័ន្ធផ្សេងទៀតរបស់ប្រតិបត្តិករ **ថ.ធ.ឌ.** ត្រូវចាត់ទុកជាចំណូលមិនមែនសារពើពន្ធ ដែល ត្រូវគ្រប់គ្រង ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន ពាក់ព័ន្ធនឹង ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។

## ជំពូកទី៧
## ការដោះស្រាយវិវាទ

**មាត្រា៣៤.-**

ក្រៅពីករណីបទល្មើសព្រហ្មទណ្ឌ គ្រប់វិវាទពាក់ព័ន្ធនឹងការគ្រប់គ្រងនិងការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** ដូចមានចែងក្នុងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ អាចត្រូវបាន ដោះស្រាយដោយប្រតិបត្តិករ **ថ.ធ.ឌ.** តាមរយៈការផ្សះផ្សា។

នីតិវិធីនៃការផ្សះផ្សានិងកម្រៃសេវាសម្រាប់ការដោះស្រាយវិវាទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្នុងករណីការផ្សះផ្សាមិនទទួលបានជោគជ័យ ភាគីនៃវិវាទអាចប្ដឹងទៅតុលាការមានសមត្ថកិច្ចដើម្បី ដោះស្រាយអនុលោមតាមនីតិវិធីដូចមានចែងក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា៣៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។



គេហទំព័រ ឯកសារមន្ត្រីរាជការ - https://t.me/oa_channel

**មាត្រា៣៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៩កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ
## នៃអនុក្រឹត្យលេខ.២០៧..អនក្រ.បក ចុះថ្ងៃទី..២៦...ខែកក្កដា..ឆ្នាំ២០២៣
## ស្តីពីការគ្រប់គ្រងថ្នាលសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថលកម្ពុជា

## សទ្ទានុក្រម

**ក**

**កំណត់ត្រាអេឡិចត្រូនិក** (Timestamp) សំដៅដល់កំណត់ត្រាដែលត្រូវបានបង្កើត ទាក់ទង ទទួល រក្សាទុក ឬដំណើរការក្នុងប្រព័ន្ធអេឡិចត្រូនិក ឬសម្រាប់បញ្ជូនពីប្រព័ន្ធអេឡិចត្រូនិកមួយទៅប្រព័ន្ធអេឡិចត្រូនិកមួយទៀត។

**ច**

**ចំនួនប្រតិបត្តិការ** (Number of transaction) សំដៅដល់ចំនួននៃការស្នើសុំផ្ទៀងផ្ទាត់ និង ការប្រើប្រាស់ទិន្នន័យ អត្តសញ្ញាណអតិថិជនឌីជីថលនៃ **អ.ឌ.ក.** មកកាន់ប្រតិបត្តិករ **ថ.ផ.ឌ.** ដែលមួយ ប្រតិបត្តិការត្រូវបានកំណត់យកនៅពេលដែលប្រតិបត្តិករ **ថ.ផ.ឌ.** ឆ្លើយតបទៅវិញដោយជោគជ័យតាម តម្រូវការនៃការស្នើសុំនោះ។

**ថ**

**ថ្នាលសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថលកម្ពុជា** (Cambodia Digital Key – CamDigiKey) សំដៅដល់ប្រព័ន្ធសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថល ដែលប្រតិបត្តិដោយប្រតិបត្តិករថ្នាល **ថ.ផ.ឌ.**។

**ន**

**នីតិបុគ្គល** (Legal entity) សំដៅដល់ក្រុមបុគ្គលជារូបវន្តបុគ្គលឬនីតិបុគ្គល ដែលមានផលប្រយោជន៍ រួមគ្នា។ នីតិបុគ្គលមានបុគ្គលភាពគតិយុត្ត។ ក្នុងឋានៈជាប្រធាននីតិ នីតិបុគ្គលមានសិទ្ធិនិងកាតព្វកិច្ចស្រប តាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**ប**

**ប្រព័ន្ធសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថល** (Electronic Know Your Customer - eKYC) សំដៅដល់ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីបង្កើតនិងផ្ទៀងផ្ទាត់ភាពត្រឹមត្រូវរបស់អតិថិជនក្នុងពិភពឌីជីថល តាមប្រព័ន្ធអេឡិចត្រូនិក ដោយពឹងផ្អែកលើឯកសារសម្គាល់អត្តសញ្ញាណដែលទទួលស្គាល់ដោយរាជរដ្ឋាភិបាល។

**យ**

**យថាភូតកម្មអត្តសញ្ញាណអតិថិជនឌីជីថល** (e-KYC authentication) សំដៅដល់ការបញ្ជាក់អំពី ភាពត្រឹមត្រូវនិងភាពអាចជឿទុកចិត្តបាននៃការកំណត់អត្តសញ្ញាណអតិថិជនឌីជីថល។

**រ**

**រូបវន្តបុគ្គល** (Physical person/Natural person) សំដៅដល់ឯកត្តបុគ្គលដែលមានបុគ្គលភាព គតិយុត្តស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។ រូបវន្តបុគ្គលរួមមានរូបវន្តបុគ្គល មានសញ្ជាតិខ្មែរនិងរូបវន្តបុគ្គលមានសញ្ជាតិបរទេស។

**រូបវន្តបុគ្គលមានសញ្ជាតិខ្មែរ** (Physical person/Natural person of Khmer nationality) សំដៅ ដល់ឯកត្តបុគ្គលមានសញ្ជាតិខ្មែរ ដែលមានបុគ្គលភាពគតិយុត្ត ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ផ្សេងទៀតជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**រូបវន្តបុគ្គលមានសញ្ជាតិបរទេស** (Physical person/Natural person of foreign nationality) សំដៅដល់ឯកត្តបុគ្គលមានសញ្ជាតិបរទេស ដែលមានបុគ្គលភាពគតិយុត្តស្របតាមច្បាប់និងលិខិតបទដ្ឋាន គតិយុត្តផ្សេងទៀតជាធរមាន។



តេឡេក្រាម ឯកសារមន្ត្រីរាជការ - https://t.me/oa_channel